ហត្ថាកសិករ លីមីតធីត
HATTHA KAKSEKAR LIMITED

# សេចក្តីជូនដំណឹងរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ លីមីតធីត

## ស្តីពី

## ការមិនទទួលយកអំណោយ និងការកម្សាន្តពីអ្នកផ្គត់ផ្គង់ ដៃគូអាជីវកម្ម និងអតិថិជន

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ លីមីតធីត យើងខ្ញុំសូមថ្លែងអំណរគុណចំពោះគ្រប់ដៃគូពាណិជ្ជកម្ម អ្នកផ្គត់ផ្គង់ និងអតិថិជនទាំងអស់ ដែលតែងតែផ្តល់ការផ្គត់ផ្គង់ ការគាំទ្រ និងការផ្តល់ទំនុកចិត្ត ចំពោះការប្រើប្រាស់សេវាកម្មរបស់គ្រឹះស្ថានយើងខ្ញុំកន្លងមក។ គ្រឹះស្ថានយើងខ្ញុំមានការប្តេជ្ញាចិត្តខ្ពស់បំផុត ក្នុងការធ្វើអាជីវកម្មដោយភាពស្មោះត្រង់ សុចរិតភាព និងការប្រតិបត្តិតាមច្បាប់ បទប្បញ្ញត្តិ គោលការណ៍អភិបាលកិច្ចល្អ រួមទាំងគោលការណ៍របស់ ហត្ថាកសិករ លីមីតធីត ក្នុងការជ្រើសរើស និងទំនាក់ទំនងជាមួយដៃគូអាជីវកម្ម អ្នកផ្គត់ផ្គង់ ក៏ដូចជាការផ្តល់សេវាកម្មជូនអតិថិជន ដោយឈរលើមូលដ្ឋានការប្រកួតប្រជែងស្មោះត្រង់ និងធានាមិនឲ្យមានទំនាស់ផលប្រយោជន៍ជាយថាហេតុណាមួយកើតមានឡើង។ គ្រឹះស្ថានយើងខ្ញុំ សូមប្តេជ្ញាដាច់ខាតក្នុងការចូលរួមប្រឆាំងលើគ្រប់ទម្រង់ទាំងអស់នៃអំពើពុករលួយ ទោះបីជាការប្រព្រឹត្តដោយផ្ទាល់ ឬដោយប្រយោលក្តី។

គ្រប់បុគ្គលិក ហត្ថាកសិករ លីមីតធីត ទាំងអស់ប្តេជ្ញាក្នុងការចូលរួមចំណែកលុបបំបាត់អំពើពុករលួយ។ ដើម្បីឆ្លើយតបនឹងបញ្ហានេះ គ្រប់បុគ្គលិកទាំងអស់របស់ ហត្ថាកសិករ លីមីតធីត បាន និងកំពុងអនុវត្តគោលនយោបាយស្តីពី ការមិនទទួលយកអំណោយដូចជាសម្ភារៈ ឬវត្ថុអនុស្សាវរីយ៍។ល។ និងការកម្សាន្ត ពីអតិថិជន ឬដៃគូអាជីវកម្មដាច់ខាត។ ដើម្បីឲ្យមានភាពងាយស្រួលសម្រាប់ ដៃគូអាជីវកម្ម អ្នកផ្គត់ផ្គង់សេវាកម្ម និងអតិថិជនទាំងអស់ ក្នុងការចូលរួមចំណែកលុបបំបាត់អំពើពុករលួយជាមួយ ហត្ថាកសិករ លីមីតធីត យើងខ្ញុំសូមធ្វើការបញ្ជាក់លម្អិតលើពាក្យថា "អំណោយ" និង "ការកម្សាន្ត" ដូចខាងក្រោម៖

១. "*អំណោយ* រួមបញ្ចូលទាំងផ្នែកហិរញ្ញវត្ថុដែលសមមូលនឹងសាច់ប្រាក់ អំណោយជាគូប៉ុន ដែលអាចប្តូរជាផលិតផល ឬសេវាកម្ម (រួមមាន សំបុត្រយន្តហោះ ឬការបញ្ចុះតម្លៃ) ដំណើរកម្សាន្ត ការស្នាក់នៅ ការចំណាយថ្លៃអាហារ។
២. *ការកម្សាន្ត* រួមមាន អាហារ ភេសជ្ជៈ ការចូលរួមកម្មវិធីសម្តែង ការប្រកួតកីឡា ការផ្សាភ្ជាប់ទៅកាន់សកម្មភាពកីឡាផ្សេងៗដូចជា ការវាយកូនហ្គោល សកម្មភាពកម្សាន្តផ្សេងៗ។

ដើម្បីឲ្យ ហត្ថាកសិករ លីមីតធីត អនុវត្ត និងគោរពទៅតាមគោលនយោបាយស្តីពី ការមិនទទួលយកអំណោយ និងការកម្សាន្តបានពេញលេញ គ្រឹះស្ថានយើងខ្ញុំ សូមធ្វើការស្នើសុំការចូលរួមពីសំណាក់អ្នកផ្គត់ផ្គង់ ដៃគូអាជីវកម្ម និងអតិថិជនទាំងអស់ មេត្តាយោគយល់ និងចូលរួមចំណែកក្នុងការប្រតិបត្តិតាមគោលនយោបាយ ក៏ដូចជាសេចក្តីជូនដំណឹងនេះ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការចូលរួម និងការយោគយល់។

**គណៈគ្រប់គ្រង ហត្ថាកសិករ លីមីតធីត**



ការិយាល័យកណ្តាល : អគារលេខ៦០៦ ផ្លូវ២៧១ សង្កាត់បឹងទំពុន ១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ប្រទេសកម្ពុជា ប្រអប់សំបុត្រ : ២០៤៤
HEAD OFFICE : # 606, Street 271, Sangkat Boeng Tumpun 1, Khan Mean Chey, Phnom Penh, Cambodia. P.O. Box: 2044
023 994 304 ( Office )
023 999 266 ( Call Center )
1800 212 222 ( Toll Free )
info@hkl.com.kh
www.hkl.com.kh